**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សារលិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ នៃព្រឹទ្ធសភា**

**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២៣ ខាងមុខនេះ ខ្ញុំបាទនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំ ប្រទានពរជ័យសិរីសួស្តី បវរមហាប្រសើរជូន **ឯកឧត្តមកិត្តិសង្គហបណ្ឌិត និងលោកជំទាវ**។

ក្នុងឱកាសដ៏មហាប្រសើរថ្លៃថ្លានេះដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវមនោសញ្ចេតនាគោរព និងដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមកិត្តិសង្គហបណ្ឌិត** ក្នុងបេសកកម្មចូលរួមដឹកនាំស្ថាប័នព្រឹទ្ធសភា ដែលធានាបាននូវនីតិរដ្ឋ និងការអភិវឌ្ឍលើគ្រប់វិស័យ សំដៅចូលរួមជាឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏រីករាយនិងថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **ឯកឧត្តមកិត្តិសង្គហបណ្ឌិត និងលោកជំទាវ** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានព្រះពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិសង្គហបណ្ឌិត អនុប្រធានទី២ នៃព្រឹទ្ធសភា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ចន្ទ ១១រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ.សុខា

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh